ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 10 / 2012
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ០២ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១១៥

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ដាវ អានសាន, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William SMITH, លោក វេង ហ៊ត, លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោកស្រី Beini YE, លោកស្រី ស៊ិន សុវន, លោក វ៉េន ពៅ. |
| សាក្សី៖ លោក ខៀវ អេន (TCW-320) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុធាវី |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK. |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៣ | បញ្ចប់ម៉ោង៖ ១០.៥៣ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.២៥ | បញ្ចប់ម៉ោង៖១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៤៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី TCW-320, TCW-428 | មេធាវីការពារក្តី អៀង សារី | ០៩.០៣ | ០៩.០៣ |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ | មេធាវីការពារក្តី នួន ជា | ១២.០៣ | ១២.០៤ |
| ការតាំងសំណួរទៅសាក្សី ខៀវ អេន (TCW-320) | មេធាវីការពារក្តី នួន ជា | ០៩.០៤ | ១៤.១៩ |
| សេចក្តីសម្រេចលើសំណើរបស់ នួនជា ក្នុងការតាំងសំណួរទៅសាក្សីទាក់ទងនឹងការ ទំនាក់ទំនងរវាងសាក្សី | អង្គជំនុំជម្រះ | ០៩.៥២ | ១០.០០ |
| សេចក៏សម្រេចលើសំណើរបស់ នួន ជា | អង្គជំនុំជម្រះ | ១៤.១៤ | ១៤.១៧ |

| | | | |
|---|---|---|---|
| ក្នុងការតាំងសំណួរទាក់ទងនឹងព្រឹត្តការណ៍ផ្សេង ក្រៅពីយុត្តាធិការពេលវេលារបស់អវតក | | | |
| កិច្ចប្រជុំពិភាក្សាអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី និងការអវត្តមាននៅក្នុងដំណើរការសវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា<br>មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ១៥.០៨<br>១៥.១២<br>១៥.១៥<br>១៥.១៦<br>១៥.២៧<br><br>១៥.៣១ | ១៥.១២<br>១៥.១៥<br>១៥.១៥<br>១៥.២៧<br>១៥.៣១<br><br>១៥.៤២ |
| ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានអាន កថាខណ្ឌ ផ្នែកពាក់ព័ន្ធដែលនៅសេសសល់ ក្នុងសំណុំរឿងលេខ០០២/០១ វគ្គទី៣ | អង្គជំនុំជម្រះ | ១៥.៤៦ | ១៦.០៧ |

## សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការ**

ជនជាប់ចោទ អៀង សារី (ឯកសារ E229) ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី ខៀវ អេន និងសាក្សី មាស វឿន។ អង្គជំនុំជម្រះបានសម្រេចបន្តដំណើរការនីតិវិធីដោយអវត្តមានជនជាប់ចោទ អៀង សារី តាមការព្រមព្រៀងរបស់ជនជាប់ចោទ។

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ (ម៉ោង ១២.០៤) បានស្នើសុំលះបង់សិទ្ធិមានវត្តមាននិងសម្រេចតាមការស្នើសុំរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។

**ការតាំងសំណួរទៅសាក្សី ខៀវ អេន (TCW-320)**

មេធាវីការពារក្តី នួន ជា បានបញ្ចប់ការតាំងសំណួរទៅសាក្សី ខៀវ អេន។

**សេចក្តីសម្រេចលើសំណើរបស់ នួន ជា ក្នុងការតាំងសំណួរទៅសាក្សីទាក់ទងនឹងការទំនាក់ទំនងរវាងសាក្សី**

មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅសាក្សី ខៀវ អេន អំពីការទំនាក់ទំនងជាមួយសាក្សីគីម វុន ដែលបានផ្តល់សក្ខីកម្មផងដែរអំពីក្រសួងឃោសនាការ។ អង្គជំនុំជម្រះបានប្រាប់ទៅមេធាវីថា សវនាការនៅពេលនេះមិនអនុញ្ញាតិឲ្យមេធាវីតាំងសំណួរដើម្បីមោឃភាពនៃការស៊ើបអង្កេត ឬក៏នីតិវិធីនៃការស៊ើបអង្កេតនោះទេ។ មេធាវីបានស្នើសុំឲ្យមានការសម្រេចពីអង្គជំនុំជម្រះទាំងមូលលើបញ្ហានេះ។ អង្គជំនុំជម្រះបានបញ្ជាក់ថាការតាំងសំណួរនេះមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវធ្វើសវនាការនោះទេ និងបានណែនាំមេធាវីឲ្យតាំងសំណួរអំពីអង្គហេតុដែលកំពុងធ្វើសវនាការនាពេលនេះ។

**សេចក្តីសម្រេចលើសំណើរបស់ នួន ជា ក្នុងការតាំងសំណួរទាក់ទងនឹងព្រឹត្តការណ៍ផ្សេងក្រៅពីយុត្តាធិការពេលវេលារបស់ អវតក**

មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅសាក្សីទាក់ទងនឹងតួនាទីរបស់ យ៉ុន យ៉ាត នៅក្នុងផ្នែកឃោសនាការក្រោយខែមករា ឆ្នាំ ១៩៧៩។ អង្គជំនុំជម្រះសម្រេចមិនអនុញ្ញាតិឲ្យមានការតាំងសំណួរនៅក្រោយវិសាលភាពនៃការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ។

**កិច្ចប្រជុំពិភាក្សាអំពីបញ្ហាសុខភាពរបស់ជនជាប់ ចោទ អៀង សារី និងការអវត្តមាននៅក្នុងដំណើរការសវនាការ**

អង្គជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការធ្វើសវនាការនៅពេលខាងមុខ ក្នុងអំឡុងពេលដែលកំពុងរង់ចាំការធ្វើបុរេរោគវិនិច្ឆ័យ និងរោគវិនិច្ឆ័យនៃស្ថានភាពសុខភាពរបស់ជន

ជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងត្រូវកំណត់ ថាតើត្រូវស្តាប់សក្ខីកម្មសាក្សីណាខ្លះ។

មេធាវីការពារក្តី អៀង សារី បានប្រមើមើលថា មិនមានការពន្យារដំណើរការសវនាការនៅពេលអនាគតដ៏ខ្លីនោះទេ ដោយហេតុថា លោក អៀង សារី បានធ្វើលិខិតលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សីចំនួនប្រហែល ២០នាក់។ ប្រសិនបើសាក្សីក្នុងចំណោមនោះបានលើកបញ្ហាណាមួយដែលមេធាវីមិនរំពឹងទុកថា នឹងពិភាក្សាអំពី លោក អៀង សារី សហព្រះរាជអាជ្ញាបានយល់ស្របឱ្យកោះហៅ សាក្សីនោះមកផ្តល់សក្ខីកម្មម្តងទៀត។ លោក អៀង សារី ក៏បានអនុញ្ញាតិឱ្យមេធាវីរបស់គាត់ចូលរួមដំណើរការសវនាការទាក់ទងនឹងឯកសារក្នុងករណីអវត្តមានរបស់គាត់ផងដែរ។ មេធាវីការពារក្តី ខៀវ សំផន និង នួន ជា បានគាំទ្រសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី អៀង សារី។

សហព្រះរាជអាជ្ញា បានយល់ស្របជាមួយមេធាវីការពារក្តី អៀង សារី ដែលថាការជំនុំជម្រះនឹងដំណើរការដោយមិនមានការពន្យារពេលរហូតដល់ឈប់សម្រាកបុណ្យភ្ជុំអែល ឆ្នាំ២០១២។ សាក្សីដែលលោក អៀង សារី បានលះបង់សិទ្ធិនោះនឹងមកផ្តល់សក្ខីកម្មអំពីបទល្មើសនៃការជម្លៀសដោយបង្ខំ និងមិនទាក់ទងនឹងអំពើប្រព្រឹត្តរបស់ជនជាប់ចោទនោះទេ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាយល់ថា អៀង សារី គួរតែលះបង់សិទ្ធិចំពោះសាក្សីផ្សេងទៀត។ សហព្រះរាជអាជ្ញា មិនយល់ថា នឹងមានការពន្យារពេលដែលកើតឡើងដោយសារតែបញ្ហាជំងឺរបស់ អៀង សារី នោះទេ ការផ្លាស់ប្តូរតែមួយគឺការស្តាប់សក្ខីកម្មសាក្សីទាក់ទងនឹងការជម្លៀសដោយបង្ខំអាចឆាប់ជាងផែនការកំណត់។

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របថាអង្គជំនុំជម្រះគួរដំណើរការសវនាការក្នុងការស្តាប់សក្ខីកម្មសាក្សីនៅលើអង្គហេតុការជម្លៀសដោយបង្ខំ។

អង្គជំនុំជម្រះបានសួរទៅមេធាវីការពារក្តី អៀង សារីឱ្យធ្វើការបញ្ជាក់ថាតើការលះបង់សិទ្ធិរបស់លោក អៀង សារី មានលក្ខខណ្ឌកំណត់ដែរឬយ៉ាងណា។ មេធាវីការពារក្តីបានឆ្លើយថាប្រសិនបើសាក្សីដែលមេធាវីមិនរំពឹងទុកថាធ្វើសក្ខីកម្មអំពីអំពើរបស់ លោក អៀង សារី សហព្រះរាជអាជ្ញាបានយល់ស្របឱ្យមេធាវីក្នុងការលើកពីបញ្ហានោះនៅពេលក្រោយបន្ទាប់ពីបានពិភាក្សាជាមួយលោក អៀង សារីហើយ ជាជាងការកាត់ផ្តាច់ដំណើរការនីតិវិធី។

អង្គជំនុំជម្រះបានសួរទៅមេធាវីការពារក្តី អៀង សារីឱ្យធ្វើការបញ្ជាក់ពីវិសាលភាពនៃការលះបង់សិទ្ធិចំពោះសាក្សី TCW-428។ មេធាវីការពារក្តីបានឆ្លើយថាការលះបង់សិទ្ធិរបស់ជនជាប់ចោទ អៀង សារី គឺគ្របដណ្តប់រាល់អង្គហេតុទាំងអស់ដែលទាក់ទងនឹងសំណុំរឿងលេខ០០២/០១ មិនត្រឹមតែអង្គហេតុរចនាសម្ព័ន្ធឃោឃានោះទេ។

**ការអានដីកាដំណោះស្រាយពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿងលេខ០០២/០១ វគ្គទី៣**

ក្រឡាបញ្ជីអង្គជំនុំជម្រះបានអានដីកាដំណោះស្រាយពាក់ព័ន្ធនឹងផ្នែកដែលនៅសេសសល់ក្នុងសំណុំរឿងលេខ ០០២/០១ វគ្គទី៣ តាមការណែនាំពីអង្គជំនុំជម្រះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/438 | D279/4 | 00373429-00373438 00375870-00375877 00426427-00426435 | កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខៀវ អេន KHIEV Ĕn Written Record of Interview of KHIEV Ĕn ខៀវ អេន Procès verbal d'audition de témoin KHIEV Ĕn ខៀវ អេន | P | 00373434 | 00375874 | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចបន្តដំណើរការសវនាការ ដោយអវត្តមានជនជាប់ចោទអៀងសារី តាមការស្នើសរបស់ជនជាប់ចោទ (ឯកសារ E229) និងសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី ខៀវ អេន (TCW-320) ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ។
- បង្គាប់ឲ្យក្រឡាបញ្ជីអង្គជំនុំជម្រះអានកថាខណ្ឌដែលនៅសេសសល់ក្នុងសំណុំរឿងលេខ០០២/០១ វគ្គទី៣
- ក្រឡាបញ្ជីអង្គជំនុំជម្រះនិងបន្តអានកថាខណ្ឌពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយសំណុំរឿងលេខ០០២/០១ នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ បន្ទាប់មកអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សី TCW-428។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

**សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ០៣ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។**

ភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២
ក្រឡាបញ្ជី ... ក្រឡាបញ្ជី

សែ កុ... Roger PHILLIPS